ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កងរាជអាវុធហត្ថលើផ្ទៃប្រទេស
អនុគណៈកម្មការជ្រើសរើសយោធិន
នៃកងរាជអាវុធហត្ថ
លេខ : ០០៤/ ត.វ.៣ /២០២៤

# សេចក្តីជូនដំណឹង

- បានឃើញសេចក្តីសម្រេចលេខ ៧៨សសរ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការជ្រើសរើសពលទាហានថ្មី
- បានឃើញសេចក្តីសម្រេចលេខ ៨១សសរ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការជ្រើសរើសពលទាហានថ្មី
- បានឃើញប្រកាសរបស់ក្រសួងការពារជាតិលេខ ០១៦ ប្រក.កពជ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការជ្រើសរើសពលទាហាន
- បានឃើញប្រកាសរបស់ក្រសួងការពារជាតិលេខ ០១៨ ប្រក.កពជ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការជ្រើសរើសពលទាហានថ្មី បំពេញក្របខ័ណ្ឌឱ្យបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- បានឃើញសេចក្តីសម្រេចលេខ១២២/២០២៤សសរ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៤ របស់កងរាជអាវុធហត្ថលើផ្ទៃប្រទេស ស្តីពីបង្កើតអនុគណៈកម្មការជ្រើសរើសយោធិន នៃកងរាជអាវុធហត្ថ

## ប្រធានអនុគណៈកម្មការ
## ជ្រើសរើសយោធិន នៃកងរាជអាវុធហត្ថ

សូមជូនដំណឹងដល់សិស្ស និស្សិត យុវជន ទាំងអស់ ជ្រាបថា៖ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស ធ្វើការជ្រើសរើសពលទាហាន ដើម្បីបំពេញក្របខ័ណ្ឌឱ្យកងរាជអាវុធហត្ថ។

ចំពោះអ្នកដែលមានបំណងចង់ចូលបម្រើការងារក្នុងកងរាជអាវុធហត្ថ ប្រកបដោយមនសិការ និងឧត្តមគតិក្នុងការបម្រើជាតិមាតុភូមិ សូមអញ្ជើញមកទំនាក់ទំនង និងទទួលយកឯកសារ(ដោយឥតគិតប្រាក់) និងដាក់ពាក្យសុំចុះឈ្មោះនៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី/ខេត្តទាំង២៥ តាមអាសយដ្ឋានដែលសាមីខ្លួនរស់នៅ រៀងរាល់ម៉ោងធ្វើការ តាមកាលបរិច្ឆេទដូចខាងក្រោម៖

១- **ចែកពាក្យ**: ចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៤

២- **ទទួលពាក្យ**: ចាប់ពីថ្ងៃទី១៧ ខែមិថុនា ដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២៤

**❋ លក្ខណសម្បត្តិ និងលក្ខខណ្ឌបេក្ខជនដែលត្រូវជ្រើសរើស៖**

១- មានសញ្ជាតិខ្មែរ ភេទប្រុស (នៅលីវ)

២- មានអាយុពី១៨(ដប់ប្រាំបី)ឆ្នាំ ដល់២៥(ម្ភៃប្រាំ)ឆ្នាំ -គិតត្រឹមថ្ងៃដាក់ពាក្យ

៣- មានកាយសម្បទាគ្រប់គ្រាន់ និងមានសុខភាពល្អ តាមតម្រូវការដើម្បីបំពេញមុខងារ

៤- មានភក្តីភាពចំពោះជាតិ មាតុភូមិ និងគ្មានជាប់ពិរុទ្ធ អំពីបទល្មើសផ្សេងៗ

៥- មាន សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទៅ ឬលិខិតបញ្ជាក់ការសិក្សា ឬសមមូលសញ្ញាបត្រ

៦- មានកម្ពស់ចាប់ពី១,៧០ម(មួយម៉ែត្រចិតសិប) ឡើងទៅ

៧- បេក្ខជនត្រូវឆ្លងកាត់ការត្រួតពិនិត្យលក្ខណសម្បត្តិ និងធ្វើតេស្តប្រឡងសមត្ថភាព

៨- បេក្ខជនត្រូវមានសុខភាព និងកាយសម្បទាល្អ(ឆ្លងកាត់ការត្រួតពិនិត្យឈាម, កាយសម្បទា និង ទឹកមូត្រ)

- **ព័ត៌មានលម្អិត សូមទំនាក់ទំនង នៅតាមបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី/ខេត្តទាំង២៥**
- **ក្នុងករណីមានភាពមិនប្រក្រតី សូមទំនាក់ទំនង**

| | | | |
|---|---|---|---|
| - លោកឧត្តមសេនីយ៍ត្រី | **អេង ហ៊ី** | ទូរស័ព្ទ | ០៨៨ ៨២៣ ៤៥៦៨ |
| - លោកវរសេនីយ៍ទោ | **អ៊ុល ចាន់សុគន្ធី** | ទូរស័ព្ទ | ០១២ ២៧៨ ៨៧០ |
| - លោកវរសេនីយ៍ទោ | **សៅ ចន្ទគ្រីស្នា** | ទូរស័ព្ទ | ០៧១ ៣៣៣ ៧៧៧៧ |

ថ្ងៃ ព្រហស្បតិ៍ ៦រោច ខែអស្សុជ.. ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣...ខែតុលា.ឆ្នាំ២០២៤

**មេបញ្ជាការរង**

**ប្រធានអនុគណៈកម្មការ**

**ជ្រើសរើសយោធិន នៃកងរាជអាវុធហត្ថ**

ឧត្តមសេនីយ៍ឯក.ស៊ិន ~សុផាន្និ